ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២

# សេចក្ដីប្រកាសព័ត៌មាន
## ការតែងតាំងចៅក្រមនៅអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក

ចៅក្រម Florence Ndepele Mwachande Mumba មកពីប្រទេសហ្សំប៊ី ត្រូវបានតែងតាំងជាចៅក្រមជំនុំជម្រះនៃអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីអគ្គលេខាធិការអង្គការសហប្រជាជាតិបានតែងតាំងគាត់ជាចៅក្រមរួចមក។ ចៅក្រម Mumba ត្រូវជំនួសលោកចៅក្រម Motoo Noguchi ដែលបានលាឈប់ក្នុងខែ កក្កដា ឆ្នាំ ២០១២ កន្លងទៅ។ ចៅក្រម Mumba បានបំពេញតួនាទីជាចៅក្រមបម្រុងនៅអង្គជំនុំជម្រះតុលាការកំពូលនៃអ.វ.ត.ក រហូតដល់ពេលមានការតែងតាំងថ្មីនេះ។

លោកស្រីចៅក្រម Mumba ត្រូវបានផ្ដល់នីតិសម្បទាដោយគណៈមេធាវី នៅក្នុងឆ្នាំ ១៩៧៣។ លោកស្រី ធ្លាប់ធ្វើជានាយិកានៃនាយកដ្ឋានជំនួយផ្នែកច្បាប់ (ឆ្នាំ ១៩៧៧) ជាស្ត្រីដំបូងដែលកាន់តួនាទីជាចៅក្រមតុលាការជាន់ខ្ពស់ (ឆ្នាំ ១៩៨០) មន្ត្រីទទួលបណ្ដឹងប្រជាពលរដ្ឋ(ឆ្នាំ ១៩៨៩) ចៅក្រមតុលាការកំពូល (១៩៩៧) ចៅក្រមនៅសាលាក្ដីព្រហ្មទណ្ឌអន្តរជាតិនៃអង្គការសហប្រជាជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ឬតុលាការ UNICTY) (ឆ្នាំ ១៩៩៧-២០០៥) អនុប្រធានតុលាការ UNICTY (ឆ្នាំ ១៩៩៩-២០០០) ចៅក្រមនៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ UNICTY និងសាលាក្ដីអង្គការសហប្រជាជាតិសម្រាប់ប្រទេសរ៉្វាន់ដា (ឆ្នាំ ២០០៣-២០០៥) និងប្រធានគណៈកម្មការបោះឆ្នោតនៃប្រទេសហ្សំប៊ី(ឆ្នាំ ២០០៨-២០១០)។ លោកស្រីធ្លាប់ធ្វើជាក្រុមប្រឹក្សានៃគណៈកម្មការអង្គការសហប្រជាជាតិស្ដីពីឋានៈស្ត្រី (ឆ្នាំ ១៩៩២-១៩៩៥) ជា មន្ត្រីជំនាញផ្នែកច្បាប់ក្នុងគណៈកម្មាធិការព្រាងពិធីសារនៃប្រទេសអាហ្វ្រិក ដើម្បីតាក់តែងធម្មនុញ្ញប្រទេសអាហ្វ្រិកស្ដីពីពលរដ្ឋ និងសិទ្ធិមនុស្ស ពាក់ព័ន្ធនឹងការបង្កើតតុលាការសិទ្ធិមនុស្សនៃប្រទេសអាហ្វ្រិក (ឆ្នាំ ១៩៩៥) និងជាក្រុមប្រឹក្សាជាន់ខ្ពស់នៃសហព័ន្ធប្រទេសអាហ្វ្រិកស្ដីពីដាហ្វួ (ឆ្នាំ ២០០៩-២០១០)។

លោកចៅក្រម Phillip Rapoza មកពីសហរដ្ឋអាមេរិក ត្រូវបានតែងតាំងជាចៅក្រមបម្រុងនៃអង្គជំនុំជម្រះតុលាការកំពូល ដោយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា បន្ទាប់ពីត្រូវបានតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

លោកចៅក្រម Rapoza ជាប្រធានសាលាឧទ្ធរណ៍នៃរដ្ឋ Massachusetts។ លោកចៅក្រម ទទួលបានសញ្ញាប័ត្រពីសាកលវិទ្យាល័យ Yale និង សាកលវិទ្យាល័យ Cornell និងទទួលបានរង្វាន់ស្នាដៃឆ្នើមនៅក្នុងការងារជាច្រើន។ លោកចៅក្រមបានធ្វើការក្នុងអាជីពផ្នែកច្បាប់អស់រយៈពេលជាង ៣៥ ឆ្នាំ ដោយធ្វើជារដ្ឋអាជ្ញា មេធាវីការពារក្ដី ចៅក្រមជំនុំជម្រះ និងចៅក្រមសាលាឧទ្ធរណ៍។ ពីឆ្នាំ ២០០៣-២០០៥ លោកចៅក្រមធ្វើជាចៅក្រមអន្តរជាតិ និងមន្ត្រីសម្របសម្រួលនៃគណៈកម្មាធិការពិសេសសម្រាប់ឧក្រិដ្ឋកម្មកម្រិតធ្ងន់ក្នុងប្រទេសទីម័រខាងកើត ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទល្មើសកម្រិតធ្ងន់ដទៃទៀត ដែលបានកើតឡើងមុនប្រទេសនេះទទួលបានឯករាជ្យ។

លោកថៅក្រមបំពេញការងារសកម្មក្នុងគម្រោងអង្គការសហប្រជាតិ ដើម្បីអភិវឌ្ឍវិស័យយុត្តិធម៌នៅប្រទេសទីម័រខាងកើត និងហៃទី ហើយលោកបានចូលរួមក្នុងកម្មវិធី និងវគ្គបណ្តុះបណ្តាលជាច្រើននៅកម្ពុជាពាក់ព័ន្ធនឹង អ.វ.ត.ក។


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោកស្រី យូកូ ម៉ៃដា**
មន្ត្រីកិច្ចការសាធារណៈ
ទូរស័ព្ទចល័តៈ +៨៥៥ (0) ១២ ៤៨៨ ៣១៩
ទូរស័ព្ទលើតុផ្ទាល់ៈ +៨៥៥ (0) ២៣ ៨៦១ ៦៣៩
សារអេឡិចត្រូនិកៈ maeday@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃៈ +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិកៈ neth.pheaktra@eccc.gov.kh